# របាយការណ៍ជាលាយលក្ខណ៍អក្សរសម្រាប់សិស្សបឋមសិក្សា និងមធ្យមសិក្សា

## ហេតុការណ៍ជុំវិញ

ក្នុងនាមជាឪពុកម្ដាយ / អ្នកថែទាំ / អាណាព្យាបាល លោកអ្នកនឹងបានទទួលរបាយការណ៍ជាលាយលក្ខណ៍អក្សរពីរច្បាប់ ជារៀងរាល់ឆ្នាំ។ របាយការណ៍ទាំងនេះនឹងជួយលោកអ្នកឱ្យបានយល់ដឹងពីរបៀបដែលកូនរបស់លោកអ្នកកំពុងរីកចំរើន និងរបៀបសាលារៀនជួយដល់ការអភិវឌ្ឍន៍របស់កូនលោកអ្នក។

គ្រូបង្រៀនធ្វើគម្រោង បង្រៀន វាយតម្លៃ និងធ្វើរបាយការណ៍អំពីការរៀនសូត្ររបស់សិស្ស ដោយប្រើប្រាស់កម្មវិធីសិក្សាអូស្ត្រាលី (Australian Curriculum)។ កម្មវិធីសិក្សាអូស្ត្រាលី កំណត់ស្តង់ដារខ្ពស់សម្រាប់អ្វីដែលជនវ័យក្មេងអូស្ត្រាលី ទាំងអស់គួរតែត្រូវបានបង្រៀន និងអ្វីដែលពួកគេគួរតែដឹងយល់ ហើយអាចធ្វើបាន ខណៈដែលពួកគេរីកចំរើនតាមរយៈសាលារៀន។

វិស័យរៀនសូត្រនីមួយមានស្តង់ដារសម្រេចមួយចំនួន។ ស្តង់ដារទាំងនេះរៀបរាប់ជាភាសាងាយយល់អំពីអ្វីដែលសិស្សគួរដឹងយល់ជាទូទៅ ហើយអាចធ្វើបាននៅចុងបញ្ចប់នៃកម្រិតថ្នាក់នីមួយ។

លោកអ្នកត្រូវបានលើកទឹកចិត្តឱ្យអានស្តង់ដារសម្រាប់ផ្នែកមុខវិជ្ជា និងកម្រិតថ្នាក់នីមួយ ហើយពេលណាដែលសិស្សត្រូវបានរំពឹងទុកថានឹងសម្រេចបាន នៅលើវ៉ិបសាយកម្មវិធីសិក្សាអូស្ត្រាលី: www.australiancurriculum.edu.au។ វ៉ិបសាយនេះក៏មានដាក់បញ្ចូលផងដែរនូវឧទាហរណ៍ដ៏ប្រយោជន៍ នៃកិច្ចការរបស់សិស្សដែលសម្រេចបាននៅកម្រិតថ្នាក់ខុសគ្នា។

## តើមានតម្រូវការអ្វីខ្លះសម្រាប់របាយការណ៍សិស្ស?

របាយការណ៍ជាលាយលក្ខណ៍ គឺគ្រាន់តែមួយវិធីមួយប៉ុណ្ណោះដែលសាលារៀនប្រាស្រ័យទាក់ទងជាមួយលោកអ្នកអំពីរបៀបដែលកូនរបស់លោកអ្នកកំពុងដំណើរការនៅសាលារៀន។

គ្រប់សាលារៀនទាំងអស់នៅក្នុងរដ្ឋអូស្ត្រាលីខាងត្បូង ផ្តល់ជូនឪពុកម្តាយ និងអ្នកថែទាំនូវរបាយការណ៍ជាលាយលក្ខណ៍អក្សរពីរច្បាប់ ជារៀងរាល់ឆ្នាំ ដែល៖

- រាយការណ៍លើគ្រប់មុខវិជ្ជាដែលកូនរបស់ពួកគេសិក្សា
- មានមូលដ្ឋានលើខ្នាតសមិទ្ធិផលប្រាំចំណុច
- ប្រើប្រាស់ភាសាដែលងាយយល់
- កំណត់ផ្នែករឹងមាំ និងផ្នែកដែលត្រូវការអភិវឌ្ឍបន្ថែមទៀត។

របាយការណ៍សិស្សថ្នាក់ 1-10 គឺផ្អែកលើកម្រិតសមិទ្ធិផល A-E ដែលអះអាងដោយការពន្យល់រៀបរាប់អំពីអត្ថន័យ ក្នុងទំនាក់ទំនងទៅនឹងការរីកចម្រើនរបស់ពួកគេ ទល់នឹងស្តង់ដារសមិទ្ធិផល។

របាយការណ៍សម្រាប់សិស្សថ្នាក់បន្ទាប់សាលាមត្តេយ្យ ប្រើប្រាស់ពាក្យរៀបរាប់អំពីការរីកចម្រើនរបស់សិស្សក្នុងឆ្នាំ ដែលយោងទៅស្តង់ដារលទ្ធផលដែលសម្រេចបាននៅកម្រិតសិស្សថ្នាក់បន្ទាប់សាលាមត្តេយ្យ។

## តើគ្រូបង្រៀនផ្តល់ពិន្ទុយ៉ាងដូចម្តេច?

គ្រូបង្រៀនប្រើប្រាស់យុទ្ធសាស្ត្រ និងឧបករណ៍វាយតម្លៃផ្សេងគ្នាមួយចំនួនធំ ដើម្បីប្រមូលផ្តុំភស្តុតាងនៃសមិទ្ធផលសិស្ស ដោយយោងទៅស្តង់ដារសមិទ្ធផលនៅក្នុងកម្មវិធីសិក្សាអូស្ត្រាលី។ ដោយផ្អែកលើភស្តុតាង គ្រូបង្រៀនវិនិច្ឆ័យដោយមានលំនឹងស្មើគ្នា ដើម្បីសម្រេចពិន្ទុល្អបំផុតមួយណាត្រូវសមគ្នានឹងស្តង់ដារដែលសិស្សបានសម្រេច។ គ្រូបង្រៀនមិនបានរំពឹងទុកថានឹងផ្តល់សំណុំពិន្ទុនីមួយៗនៅក្នុងថ្នាក់របស់ពួកគេឡើយ។

## តើសាលារៀនមានផ្តល់ទំរង់របាយការណ៍ដទៃទៀតឬទេ?

សាលារៀនប្រាស្រ័យទាក់ទងជាមួយលោកអ្នក អំពីការរៀនសូត្ររបស់កូនលោកអ្នកក្នុងលំនាំផ្សេងៗគ្នា រួមមានកិច្ចសម្ភាសន៍រវាងឪពុកម្តាយ និងគ្រូបង្រៀន។ លោកអ្នកអាចស្នើសុំកិច្ចសម្ភាសន៍នៅពេលផ្សេងទៀតដោយទាក់ទងមកសាលារៀន ហើយរៀបចំពេលវេលាសមស្របទៅវិញទៅមកដើម្បីជួបជាមួយគ្រូបង្រៀនរបស់កូនលោកអ្នក។



Government of South Australia
Department for Education and Child Development

## តើពិន្ទុ A-E មានន័យដូចម្តេច?

ពិន្ទុ A–E ឬពាក្យរៀបរាប់ដែលមានន័យស្មើគ្នា ត្រូវបានគ្រូបង្រៀនប្រើប្រាស់ដើម្បីធ្វើរបាយការណ៍អំពីសមិទ្ធផលរបស់សិស្ស ទល់នឹងស្តង់ដារសមិទ្ធិផលកម្មវិធីសិក្សាអូស្ត្រាលី។ ពិន្ទុទាំងនេះរៀបរាប់ពីសមិទ្ធិផលមួយចំនួនធំ ចាប់ពីតិចបំផុត ទៅល្អឥតខ្ចោះ។

តារាងដូចខាងក្រោមនេះ រៀបរាប់ពីពិន្ទុនីមួយៗជាពាក្យ។

| | *នៅក្នុងទំនាក់ទំនងទៅនឹងស្តង់ដារសមិទ្ធិផល កូនរបស់លោកអ្នក ...* |
|---|---|
| A | *បង្ហាញឱ្យឃើញនូវសមិទ្ធិផល**ល្អឥតខ្ចោះ** អំពីអ្វីដែលត្រូវបានរំពឹងទុកនៅក្នុងកម្រិតថ្នាក់នេះ។* |
| B | *បង្ហាញឱ្យឃើញនូវសមិទ្ធិផល**ល្អ** អំពីអ្វីដែលត្រូវបានរំពឹងទុកនៅក្នុងកម្រិតថ្នាក់នេះ។* |
| C | *បង្ហាញឱ្យឃើញនូវសមិទ្ធិផល**ជាទីគាប់ចិត្ត** អំពីអ្វីដែលត្រូវបានរំពឹងទុកនៅក្នុងកម្រិតថ្នាក់នេះ។* |
| D | *បង្ហាញឱ្យឃើញនូវសមិទ្ធិផល**មួយចំណែក** អំពីអ្វីដែលត្រូវបានរំពឹងទុកនៅក្នុងកម្រិតថ្នាក់នេះ។* |
| E | *បង្ហាញឱ្យឃើញនូវសមិទ្ធិផល**តិចបំផុត** អំពីអ្វីដែលត្រូវបានរំពឹងទុកនៅក្នុងកម្រិតថ្នាក់នេះ។* |

- ពិន្ទុ ‘A’ បង្ហាញថា សិស្សបានបង្ហាញពីចំណេះដឹងហ្មត់ចត់ និងការយល់ដឹងអំពីប្រធានបទ ហើយអាចអនុវត្តព័ត៌មាននោះនៅក្នុងស្ថានភាពដែលមិនធ្លាប់ស្គាល់។
- ពិន្ទុ ‘C’ ជាទូទៅមានន័យថាសិស្សម្នាក់ទទួលបាននូវអ្វីដែលពួកគេត្រូវបានរំពឹងទុក នៅចំណុចក្នុងការរៀនសូត្ររបស់ពួកគេ។ នេះគឺជាសមិទ្ធិផលសន្ទឹកសន្ទាប់ ដោយព្រោះតែការរំពឹងទុកខ្ពស់ដែលដាក់បញ្ចូលនៅក្នុងស្តង់ដារសមិទ្ធិផល។
- ពិន្ទុ ‘E’ មានន័យថាសិស្សកំពុងតែចាប់ផ្តើមប៉ុណ្ណោះ ដើម្បីធ្វើការឆ្ពោះទៅកាន់ស្តង់ដារសមិទ្ធិផល។

ពិន្ទុ A-E និងយោបល់ដែលមានភ្ជាប់មកជាមួយ គឺជាទ្រង់ទ្រាយមួយនៃការធ្វើរាយការណ៍ទៅឪពុកម្តាយ / ថៃទាំ / អាណាព្យាបាល។ របាយការណ៍នេះក៏អាចផ្តល់ព័ត៌មានផងដែរអំពី៖

- ផ្នែករឹងមាំ និងផ្នែកដែលត្រូវការអភិវឌ្ឍបន្ថែមទៀតរបស់សិស្ស
- យុទ្ធសាស្ត្រដើម្បីជួយដល់ការរីកចំរើនរបស់ពួកគេ
- អាកប្បកិរិយា និងការប្តេជ្ញាចិត្តដើម្បីរៀនសូត្រ
- ព័ត៌មានអំពីការអភិវឌ្ឍសង្គមរបស់ពួកគេ
- ការចូលរួមក្នុងកម្មវិធី និងសកម្មភាពសាលារៀន
- វត្តមាននៅថ្នាក់រៀន

ការសម្រេចអំពីទ្រង់ទ្រាយ និងខ្លឹមសារនៃរបាយការណ៍ដែលមានមូលដ្ឋាននៅសាលា ត្រូវបានធ្វើឡើងដោយសាលា ដោយមានការពិគ្រោះយោបល់ជាមួយសហគមន៍របស់ពួកគេ។

## តើរបាយការណ៍សិស្សទាំងអស់ត្រូវតែមានដាក់បញ្ចូលពិន្ទុ A-E ឬ?

ការរីកចំរើន និងសមិទ្ធិផលរបស់សិស្សមួយចំនួន នឹងត្រូវបានធ្វើរបាយការណ៍ទល់នឹងស្តង់ដារសមិទ្ធិផលមួយដែលផ្តល់សមល្អបំផុតនឹងកម្រិតសមិទ្ធផលបច្ចុប្បន្នរបស់ខ្លួន។ ការនេះអាចកើតមានឡើងនៅតាមផ្នែកនៃការរៀនសូត្រខ្លះ ឬទាំងអស់។ ផ្សេងទៀតនោះ សមិទ្ធិផលរបស់ពួកគេអាចត្រូវបានធ្វើរបាយការណ៍ទល់នឹងគោលដៅនៃផែនការរៀនសូត្រផ្ទាល់ខ្លួនរបស់ពួកគេ។ សាលារៀនត្រូវបានរំពឹងទុកថានឹងចរចាទាំងកម្មវិធីសិក្សារបស់សិស្ស និងការរៀបចំធ្វើរបាយការណ៍សមស្របសម្រាប់សិស្សមួយចំនួនដែលមានឪពុកម្តាយ / ថៃទាំ / អាណាព្យាបាលសិស្សផងដែរ ប្រសិនបើសមរម្យ ហើយនិងអ្នកជំនាញពាក់ព័ន្ធដទៃទៀត។

ការនេះអាចកើតឡើងចំពោះសិស្សមួយចំនួនដែលមានពិការភាព និងសិស្សមកដល់ថ្មីដែលមានសិទ្ធិទទួលបាន នៅក្នុងសាលារៀនសម្រាប់សិស្សទូទៅ។ សិស្សដែលបានចាកចេញពីកម្មវិធីរៀនភាសាអង់គ្លេសល្អិតល្អន់ / កម្មវិធីសម្រាប់សិស្សមកដល់ ថ្មី (IELP/NAP) អាចនឹងមិនបានផ្តល់ពិន្ទុ A-E រហូតដល់ទៅប្រាំមួយឆមាស បន្ទាប់ពីពួកគេចាកចេញពីកម្មវិធី។ សិស្សទាំងឡាយដែលនៅក្នុង IELP/NAP ទទួលបានរបាយការណ៍មួយដែលអធិប្បាយអំពីសមិទ្ធិផលរបស់ពួកគេ ជាជាងការទទួលបានពិន្ទុ A-E។



Government of South Australia
Department for Education and Child Development